**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមជនជាតិជប៉ុននៅកម្ពុជា**

លេខៈ 001 - SP

**គោរពជូន**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា**

ជាបឋម ខ្ញុំបាទ **កុអ៊ិជិ តាគូម៉ា** ជាប្រធានសមាគមជនជាតិជប៉ុននៅកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃស្ថាប័ន និងអង្គភាពនានានៃរាជរដ្ឋាភិបាលកម្ពុជា** ដែលជានិច្ចកាលតែងតែខិតខំប្រឹងប្រែងអនុវត្តវិធានការ ដើម្បីការពារ បង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩។ យើងខ្ញុំទាំងអស់គ្នាជាសមាជិក សមាជិកា នៃសមាគមជនជាតិជប៉ុននៅកម្ពុជា ដែលសមាគមនេះត្រូវបានរៀបចំបង្កើតឡើងដោយជនជាតិជប៉ុន ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា តែងតែគោរព និងប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ យើងខ្ញុំតែងតែខិតខំចូលរួមសហការអស់ពីសមត្ថភាព និងកម្លាំងកាយកម្លាំងចិត្តជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្តារ និងកែខៃបញ្ហាដែលកំពុងជួបប្រទះ ដើម្បីឲ្យស្ថានភាពកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានធូរស្រាលឡើងវិញឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

មួយវិញទៀត ទាក់ទងទៅនឹងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សមាគមជនជាតិជប៉ុននៅកម្ពុជាបានទទួលការបញ្ជាក់ពីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោម ៖

"ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាបានទទួលការបញ្ជាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាថា រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អនុសាសន៍ណែនាំឲ្យចាក់វ៉ាក់សាំង ក៏ប៉ុន្តែការចាក់វ៉ាក់សាំងមិនមែនជាកាតព្វកិច្ចបុគ្គលទេ។"

យើងខ្ញុំទាំងអស់គ្នាដែលជាសមាជិក សមាជិកា នៃសមាគមជនជាតិជប៉ុននៅកម្ពុជាបានសម្រេចដោយផ្អែកលើខ្លឹមសារដូចដែលមានចែងខាងលើ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត បុគ្គលម្នាក់ៗអាចមានសិទ្ធិដោយឯករាជ្យក្នុងការទទួលការចាក់វ៉ាក់សាំង ឬមិនទទួលការចាក់វ៉ាក់សាំង។

ហេតុដូច្នេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនៃនាំស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា** មេត្តាជួយសម្របសម្រួលដោយសេចក្តីអនុគ្រោះជាទីបំផុតចំពោះជនជាតិជប៉ុនដែលមានបំណងទទួលការចាក់វ៉ាក់សាំង ដើម្បីអាចឲ្យពួកគេទទួលបាននូវការចាក់វ៉ាក់សាំងឲ្យដូចប្រជាជនកម្ពុជាផងដែរ។

ក៏ប៉ុន្តែ ចំពោះជនជាតិជប៉ុនដែលពុំមានបំណងទទួលការចាក់វ៉ាក់សាំង សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា** មេត្តាយោគយល់ដោយសេចក្តី

អនុគ្រោះជាទីបំផុត និងជួយសម្របសម្រួល ដើម្បីកុំឲ្យមានការបង្ខិតបង្ខំក្នុងការទទួលការចាក់វ៉ាក់សាំង ឬមិនត្រូវឲ្យមានការរើសអើងដោយសារពួកគេមិនទទួលការចាក់វ៉ាក់សាំង។

សូមជម្រាបជូនជាព័ត៌មានថា យើងខ្ញុំក៏បានទទួលការពិគ្រោះយោបល់ពីសំណាក់សមាជិក សមាជិកា នៃសមាគមយើងខ្ញុំថា នៅតាមតំបន់មួយចំនួន អាជ្ញាធរមានសមត្ថកិច្ចកំពុងបានរៀបចំនីតិវិធីក្នុងការចាក់វ៉ាក់សាំងសម្រាប់ជនបរទេសរួមទាំងជនជាតិជប៉ុន ដោយសារតែមានការយល់ច្រឡំថា ការចាក់វ៉ាក់សាំងគឺជាកាតព្វកិច្ច។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃស្ថាប័ន និងអង្គភាពនានានៃរាជរដ្ឋាភិបាលកម្ពុជា** ដែលបានអានលិខិតនេះ សូមត្រួតពិនិត្យឡើងវិញនូវព័ត៌មានខាងលើ ដែលសមាគមជនជាតិជប៉ុននៅកម្ពុជាបានទទួលការបញ្ជាក់ពីស្ថានទូតជប៉ុន និងសូមមេត្តាគោរពឆន្ទៈសេរីរបស់ជនជាតិជប៉ុនម្នាក់ៗ ក្នុងការជ្រើសរើសការទទួលចាក់វ៉ាក់សាំង ឬមិនទទួលចាក់វ៉ាក់សាំង ដោយសេចក្ដីអនុគ្រោះជាទីបំផុត។

សូមជម្រាបជូនបន្ថែមទៀតថា វ៉ាក់សាំងដែលកំពុងត្រូវបានប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ មិនទាន់ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលជប៉ុននៅឡើយទេ។ សមាគមជនជាតិជប៉ុននៅកម្ពុជាបានស្នើសុំរដ្ឋាភិបាលជប៉ុនឲ្យសម្របសម្រួលដល់ជនជាតិជប៉ុន ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចទទួលនូវការចាក់វ៉ាក់សាំង ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលជប៉ុន ឬអង្គការសុខភាពពិភពលោក (WHO) ដោយមានគោលបំណងគាំទ្រការការពារ បង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ តាមរយៈការចាក់វ៉ាក់សាំង ឲ្យដូចគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយោគយល់ដោយសេចក្ដីអនុគ្រោះជាទីបំផុតរបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី**។

ថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១

**ប្រធានសមាគម**

ហត្ថលេខា និងត្រា

小吊理恵

JACAM

**កូអុិជិ តាគួអ៊ី**

**<u>ចម្លងជូន ៖</u>**

-ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

-សមាគមពាណិជ្ជកម្មជប៉ុនប្រចាំកម្ពុជា